ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១.សារណ៍

# សារាចរណែនាំ
# ស្តីពី
# ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអកូឡូស៊ីសេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាពនិងចីរភាព ដើម្បីចៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

## ១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយនិងត្រូវរៀបចំដាក់តូបផ្ទាំងឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈនិងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើលនិងការពារសុវត្ថិភាពជូនសាធារណជននិងអ្នកទេសចរ។

## ២- ដីចំណីឆ្នេរសមុទ្រនិងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតងនិងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

### ២.១- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០(ហាសិប)ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

### ២.២- ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ទី១- ដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើននិងមានលក្ខណៈជាទីប្រជុំជនឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥(ដប់ប្រាំ)ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្ថូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរគ្រប់ប្រភេទចូលចតក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជននិងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្របនិងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់ និងទីតាំងដែលមានសក្តានុពលខ្លាំងនិងចាំបាច់សម្រាប់សាងសង់កំពង់ផែ។

- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈនិងទេសចរណ៍ដូចជា៖
  - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅកែកំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្របនិងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
  - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ(Aquariums) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
  - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

ទី២- ដីចំណីឆ្នេរសមុទ្រស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើននិងមិនមែនជាទីប្រមុំជនការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែ ពាណិជ្ជកម្ម ឬកំពង់ផែនេសាទ។ ចំពោះកំពង់ផែដែលមានស្រាប់ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ ត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាពសុខុមាលភាពនិងការកាត់បន្ថយហានិភ័យផ្សេងៗ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផែទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មីឬដែលមានស្រាប់ទៅតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជា សំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាសនិងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍឬឲ្យមានសំណង់ផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

## ៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះនិងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្មក្នុងគោលដៅ

ថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ (ដប់ប្រាំ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

## ៤- តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់នេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិនិងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកសញ្ញាពាណិជ្ជកម្ម។

## ៥- ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ

ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រដែលតភ្ជាប់ទៅចំណុចប្រសព្វនឹងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រត្រូវ៖

- រក្សាទុកចិញ្ចើមសងខាងយ៉ាងតិច៦(ប្រាំមួយ)ម៉ែត្រ ចំពោះកំណាត់ផ្លូវសាធារណៈនៅក្នុងតំបន់រណប ដើម្បីរៀបចំឲ្យមានសួនច្បារ ការដាំស្មៅ ការដាំដើមឈើព្រមទាំងផ្លូវថ្មើរជើងស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឲ្យមានសួនច្បារ ការដាំស្មៅ និងការដាំដើមឈើអមសងខាងតាមស្ថានភាពជាក់ស្តែងនិងស្របតាមបទដ្ឋានបច្ចេកទេសចំពោះផ្លូវថ្មើរជើងដែលមានស្រាប់ឬបង្កើតថ្មី
- ត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ចំពោះផ្ទៃដីឬលំហសាធារណៈដែលស្ថិតនៅជាប់ផ្លូវសាធារណៈដែលមានស្រាប់ឬបង្កើតថ្មី ដើម្បីលើកកម្ពស់សោភណភាពបរិស្ថាននិងជាការបើកច្រកខ្យល់ជំនោរសមុទ្រ។

### ៦- ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ

ដៃសមុទ្រគឺជាផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រ ត្រូវកំណត់ចម្ងាយ៣០(សាមសិប)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬកប៉ាល់ចេញចូលបាន បណ្ដែតបានគឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្ដែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្ដែតបាន ត្រូវកំណត់ចម្ងាយ២០(ម្ភៃ)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

ផ្លូវសាធារណៈតាមបណ្ដោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្ដែតបាន គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្ដែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬកប៉ាល់ចេញចូលបាន បណ្ដែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបានឬបណ្ដែតបាន។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈខាងលើនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្ដួចផ្ដើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម ក្នុងគោលដៅថែរក្សាការពារនិងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានដីចំណីផ្លូវយ៉ាងតិច១០(ដប់)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

នៅតាមបណ្ដោយផ្លូវសាធារណៈនេះត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្ដាញបៃតង ដើម្បីលើកកម្ពស់សោភណភាពនិងបរិស្ថាន។

ការអភិវឌ្ឍជាសំណង់អគារផ្សេងៗនៅជាប់ផ្លូវសាធារណៈនេះ ត្រូវមានសន្ទស្សន៍ទាបដូចក្នុងតំបន់រណបតាមបណ្ដោយផ្លូវជាប់នឹងដីចំណីឆ្នេរសមុទ្រដែរ។

### ៧- កោះ

កោះ ជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

#### ៧.១- ការប្រើប្រាស់និងការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាបណ្ដោះអាសន្ននិងមិនទៀងតាមរយៈកិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍកោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់

ប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទប្បញ្ញត្តិជាធរមានឬតាមផែនការអភិវឌ្ឍដែលរាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែងនិងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវរក្សានិងការពារធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិប)ភាគរយ
- ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥%(សាមសិបប្រាំ) ភាគរយ ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិច៥០% (ហាសិប) ភាគរយ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំឲ្យមានលំហសាធារណៈនិងតំបន់កម្សាន្តនានាឲ្យបានច្រើនជាអតិបរមាដើម្បីជំរុញការមកលេងកម្សាន្តរបស់សាធារណជននិងអ្នកទេសចរ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចអនុញ្ញាតឲ្យសាធារណជនទូទៅឬអ្នកទេសចរចេញចូលបាន
- ត្រូវរៀបចំឲ្យមានតំបន់កម្សាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈ ត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេសនិងតម្រូវការនៃការប្រើប្រាស់យូរអង្វែង
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍។

**៧.២- ការអភិវឌ្ឍនិងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ**

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍកោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជនឬផ្តល់សិទ្ធិឲ្យឯកជនធ្វើការអភិវឌ្ឍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍកោះ ជាលក្ខណៈរូបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការអភិវឌ្ឍនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាបឬមធ្យម
- ត្រូវការពារធនធានធម្មជាតិនិងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិបភាគរយ)
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ/

- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍ប្រវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារ សួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធលូបង្ហូរ ប្រព័ន្ធចម្រោះទឹកកខ្វក់ ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកទេសចរនិងសាធារណជនទូទៅចេញចូលបាន តាមស្ថានភាពជាក់ស្តែងនិងមានទីតាំងសមស្រប
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ មុនពេលធ្វើប្រព្រឹត្តកម្ម
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះ ដើម្បីគោលដៅទេសចរណ៍

៧.៣- ចំពោះកោះដែលមិនមានភាពអំណោយផលដល់ការប្រើប្រាស់និងមិនអាចធ្វើការអភិវឌ្ឍផ្សេងៗបាន ត្រូវរក្សាទុកសភាពដើមសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ទេសភាពសមុទ្រ។

## ៨. ដែនទឹកសមុទ្រ

ដែនទឹកសមុទ្រ សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ។

ដែនទឹកសមុទ្រ ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនានា ដូចជា ផ្កាថ្ម ត្រីធំតូចចម្រុះពណ៌ និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។

ការជិះនាវាឬទូកទេសចរណ៍គ្រប់ប្រភេទ ដូចជាទូកម៉ាស៊ីន អូប័រ ម៉ូតូទឹក ជាដើម អាចធ្វើឡើងតែក្នុងបរិវេណអនុញ្ញាតប៉ុណ្ណោះដើម្បីសុវត្ថិភាពអ្នកទេសចរនិងជីវៈចម្រុះ។

ការអភិវឌ្ឍកំពង់ផែទេសចរណ៍ឬទីតាំងកម្សាន្តបណ្តែតទឹកនិងក្នុងទឹកនានា ត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា ដើម្បីពិនិត្យភាពសមស្របនៃទីតាំង តាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។

ការនេសាទក្នុងតំបន់ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះត្រូវហាមឃាត់ លើកលែងតែការនេសាទជាលក្ខណៈទេសចរណ៍ដោយប្រើប្រាស់ឧបករណ៍នេសាទគ្រួសារ។

ការបូមខ្សាច់និងការសាងសង់សំណង់ផ្សេងៗនៅក្នុងដែនទឹកសមុទ្រ ដូចជាស្ថានីយសិក្សាស្រាវជ្រាវអំពីសមុទ្រ ស្ថានីយរុករករ៉ែជាដើម ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល។

រាល់ទីតាំងសំណង់លើទឹកទាំងអស់ ត្រូវរក្សាច្រកផ្លូវនាវាធំៗចេញចូលកំពង់ផែ។

## ៩. ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ

៩.១- រាល់ការប្រគល់សិទ្ធិឲ្យឯកជនធ្វើការវិនិយោគនិងអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- រៀបចំឲ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីអាចឲ្យភ្ញៀវទេសចរនិងសាធារណជនចេញចូលដើរលេងកម្សាន្តនិងប្រើប្រាស់បាន។/.

– អនុវត្តតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត

– ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឲ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ

– ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឲ្យបានត្រឹមត្រូវម៉ត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

៩.២- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

១០- សារាចរណែនាំនេះមិនមានផលប្រតិសកម្មទេ។

១១- សារាចរណែនាំនេះមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ទេ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ចនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាពនិងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ